| Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|

**2019 PUBLIC EXAMINATION**

# Khmer

## Continuers Level

**Wednesday 23 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2019*

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

1. (a) How is Bona feeling when he leaves this message? Support your answer with evidence from the text. **2**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

(b) What does Bona ask his mother and Sarom to do? **2**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) How does the daughter think her mother would feel about her getting a tattoo? **1**

(b) Describe the tradition of tattoos in Cambodia, according to the father. **4**

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) Compare the opinions of Puttra and Reasey about the television program. **3**

| Puttra | Reasey |
|---|---|
| • | • |
| • | • |
| • | • |

(b) Why is Puttra not interested in being a contestant on the program? **3**

___

___

___

___

___

___

___

___

___

## **Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 4**

4. Explain what the newsreader is referring to when she says, ‘ដំណឹងល្អពីខេត្តកំពត’. **3**

ចូរអ្នកពន្យល់ថា តើអ្នកអានពត៌មាននិយាយសំដៅទៅលើអ្វីពេលគាត់ថា ‘ដំណឹងល្អពីខេត្តកំពត’។

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. (a) What is Vuthy planning to do? **3**

តើវុទ្ធីកំពុងគ្រោងធ្វើអ្វី?

(b) What does the mother feel about her son's plans? Support your answer with evidence from the text. **4**

តើម្ដាយមានអារម្មណ៍យ៉ាងណាចំពោះគំរោងការរបស់កូនគាត់?
ចូរគាំទ្រចំឡើយរបស់អ្នកដោយស្រង់ភ័ស្តុតាងពីអត្ថបទ។

Marks

You may make notes in this space. These notes will NOT be assessed.

**Text 6**

6. (a) What challenges does Sinoun face at the moment? **3**

តើស៊ីនួនប្រឈមមុខទៅនឹងអ្វីខ្លះក្នុងពេលនេះ?

(b) Why did Sinoun decide to follow her parents' traditions? **2**

ហេតុអ្វីបានជាស៊ីនួនសម្រេចចិត្តធ្វើតាមទំនៀមទំលាប់របស់មាតាបិតានាង?

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2019**

**Section 1: Listening and Responding**

**PART A**

***Text 1***

(Caller: male)

<*beep of answering machine*>

ជំរាបសួរម៉ាក់! ខ្ញុំបូណាណ៌។ ខ្ញុំទូរស័ព្ទពីសាលាដើម្បីជំរាបម៉ាក់ថា សូមទោសយប់នេះខ្ញុំមិនបាននៅញ៉ាំបាយទេ។ ម៉ាក់ទាយទៅមើល ថាតើខ្ញុំនឹងជំរាបអ្វីទៅម៉ាក់? ខ្ញុំបានទទួលការងារដែលខ្ញុំបាន ជំរាបម៉ាក់ពីអាទិត្យមុននោះអី ហើយខ្ញុំត្រូវចាប់ផ្ដើមធ្វើការល្ងាចនេះពីម៉ោង៥ដល់ម៉ោង៨យប់។ សូមម៉ាក់មេត្តាប្រាប់សារុំអោយគាត់យកសំបុត្ររបស់ខ្ញុំទៅដាក់ក្នុងប៉ុស្តិ៍សំបុត្រអោយបានមុនម៉ោង ៦ល្ងាចផង ហើយសូមម៉ាក់មកយកខ្ញុំនៅម៉ោង៨និង១០នាទីនៅមុខស្ថានីយ៍រថភ្លើង។ ចាំទៅដល់ផ្ទះ ខ្ញុំនឹងជំរាបម៉ាក់អោយអស់អំពីកិច្ចការរបស់ខ្ញុំ។ អរគុណម៉ាក់។ ជំរាបលា!

***Text 2***

(Sreymao: female; Dad: male)

Sreymao: ប៉ា មុននឹងអញ្ជើញទៅក្រៅ ខ្ញុំអាចសួរបន្តិចបានទេ?

Dad: អូខេ មានបញ្ហាអី?

Sreymao: ខ្ញុំចង់សាក់រូបនៅលើដៃខ្ញុំមួយ។

Dad: អឺម! ប៉ាយល់ថាម៉ាក់ឯងមិនសប្បាយចិត្តទេ។

Sreymao: ខ្ញុំដឹងហើយ។ ប៉ុន្តែហេតុអីប៉ា? គ្រាន់តែសាក់តូចមួយហ្នឹង។

Dad: តាំងពីបុរាណមក មានតែបុរសទេដែលមានសាក់ ហើយគេមានសាក់មិនមែន<br>ដើម្បីលំអខ្លួនប្រាណទេ។ វាមិនមែនជាទំនៀមទំលាប់ខ្មែរទេ។

Sreymao: អញ្ចឹងគេមានសាក់សម្រាប់ធ្វើអី?

Dad: ខ្មែរទូទៅជឿថាសាក់អាចការពារខ្លួនគេពីព្រលឹងខ្មោចបិសាចនានាឬក៏អ្វីដែលចង់<br>ធ្វើអោយគេមានគ្រោះថ្នាក់។<br>វាជាការធម្មតាចំពោះទាហ៊ានក្នុងពេលសង្គ្រាមដែលមានសាក់នៅលើដើមទ្រូង ខ្នង<br>ឬក៏នៅពេញខ្លួនដើម្បីការពារនឹងគ្រាប់កាំភ្លើង។ សាក់ទាំងនោះត្រូវតែចារ<br>និងទទួលមន្តអាគមពីព្រះសង្ឃ។

Sreymao: ពេញខ្លួន! ឈឺខ្លាំងណាស់មើលទៅ។ ប៉ុន្តែប៉ា ខ្ញុំគ្រាន់តែចង់មានផ្កាតូចមួយនៅលើ<br>ដៃទេតើ មិនមែនពេញខ្លួនឯណ៎ា។

Dad: អូខេជាមួយប៉ា ពីព្រោះឯងធំពេញវ័យហើយ<br>ហើយឯងអាចសម្រេចចិត្តដោយខ្លួនឯងបាន ប៉ុន្តែចំពោះម៉ាក់ ប៉ាមិនច្បាស់ទេ។<br>ប៉ានឹងនិយាយជាមួយម៉ាក់ ចាំមើលគាត់មានប្រតិកម្មយ៉ាងម៉េចដែរ។

Sreymao: អរគុណប៉ា ប៉ាជាមនុស្សល្អបំផុត! ខ្ញុំសង្ឃឹមថាម៉ាក់នឹងយល់ព្រម។

***Text 3***

(Puttra: male; Reasey: female)

Puttra: សួស្តីរាសី! ឯងបានមើលកម្មវិធីទូរទស្សន៍ប៉ុស្តិ៍BTCយប់មិញម៉ោង៧កន្លះទេ?

Reasey: ចាំសពុត្រា ខ្ញុំបានមើល។ ខ្ញុំចូលចិត្តកម្មវិធីនេះខ្លាំងណាស់។ ឯងចូលចិត្តទេ?

Puttra: អត់ទេ ពីព្រោះខ្ញុំយល់ថាកម្មវិធីនេះហាក់ដូចជាប្រកាន់ពូជសាសន៍បន្តិច។

Reasey: ម៉េចបានជាឯងយល់យ៉ាងនេះ?

Puttra: ឯងដឹងទេ កម្មវិធីនេះធ្លាប់បានលេងច្រើនដងហើយ។ ខ្ញុំមិនដែលឃើញមានអ្នកប្រកួតជាជនជាតិអាស៊ីច្រើននៅក្នុងនោះទេ។

Reasey: អញ្ចឹងម៉េចក៏ឯងមិនចុះឈ្មោះចូលប្រកួតទៅ?

Puttra: គ្មានផ្លូវទេ ខ្ញុំមិនចង់ធ្វើខ្លួនខ្ញុំអាឡិបអាឡប់អញ្ចឹងទេ ពីព្រោះសហគមន៍ខ្មែរនឹងសើចចំអកអោយខ្ញុំ ហើយគ្រួសារខ្ញុំប្រាកដជាអាម៉ាស់មុខមិនខាន។

Reasey: មានជនជាតិអាស៊ីច្រើនណាស់ដែលមានអារម្មណ៍ដូចឯង ហើយគេក៏មិនចង់ចូលរួមប្រកួតដែរ។ ជាការគួរអោយស្តាយពីព្រោះបើមានអ្នកប្រកួតច្រើនសាសន៍វានឹងធ្វើអោយកម្មវិធីនេះកាន់តែល្អមើលជាង។

Puttra: អឺម! ឯងប្រហែលជាត្រូវ។ តើឯងយល់ថាអ្នកឈ្នះសាក់សមនឹងទទួលរង្វាន់ប៉ុណ្ណឹងទេ?

Reasey: ខ្ញុំយល់ថាសាក់សម ពីព្រោះគេជាមនុស្សមានទំនុកចិត្តដោយខ្លួនឯង មានចរិតល្អនិងចេះយកចិត្តទុកដាក់ដល់អ្នកដទៃ។

Puttra: ខ្ញុំយល់ស្រប ប៉ុន្តែខ្ញុំគិតថាមនុស្សដែលទៅចូលរួមក្នុងកម្មវិធីនោះគ្រាន់តែសំដែងដើម្បីប្រាក់ប៉ុណ្ណោះ។ ក្នុងជីវិតធម្មតា គេជាមនុស្សផ្សេងសុទ្ធសាធ។ ខ្ញុំមិនអាចធ្វើយ៉ាងដូច្នោះទេ ហើយប្រាក់រង្វាន់ដូចជាច្រើនពេកហើយ។

**PART B**

***Text 4***

(Newsreader: female)

ដំណឹងល្អពីខេត្តកំពត។
ខេត្តកំពតធ្លាប់មានឈ្មោះល្បីយូរមកហើយអំពីគុណភាពម្រេចនៅទីនោះ។ នៅក្នុងសម័យអនានិគមបារាំង ដើមម្រេចត្រូវបានគេដាំចំនួនប្រហែលមួយលានដើម។ ទោះជាយ៉ាងនេះក្តីក្រោមការត្រួតត្រារបស់ខ្មែរក្រហម ផលិតផលពីចំការម្រេចទាំងអស់ត្រូវបានគេបញ្ឈប់។

ប៉ុន្តែឥឡូវណោះផលិតផលម្រេចបានកើតឡើងវិញ។ ដើមម្រេចជាង៥ម៉ឺនដើមត្រូវបានគេដាំឡើងវិញ។
អ្នកដាំសង្ឃឹមថាខេត្តកំពតអាចនឹងមានឈ្មោះល្បីឡើងវិញក្នុងពិភពលោកថាជាតំបន់ដាំម្រេចគុណភាពខ្ពស់ ជាហេតុនាំអោយម្ចាស់ដំណាំបានទទួលប្រាក់ចំណូលច្រើនជាងមុនទៀត។

***Text 5***

Mum: វុទ្ធី ឯងទៅណាហ្នឹងកូន?

Son: ខ្ញុំទៅលេង *ហ្វ៊ុតប៊ល* ជាមួយពួកម៉ាកខ្ញុំ។

Mum: ម៉ាក់សង្ឃឹមថាឯងនឹងមិនលេងយកជាការទេ មែនទេ?

Son: អឺម! មិនច្បាស់ទេម៉ាក់។ ខ្ញុំប្រហែលជានឹងចូលលេងជាមួយក្រុមមែនទែន បើសិនជាខ្ញុំពូកែ។

Mum: ហេតុអីបានជាឯងមិនចង់លេងកីឡាអីផ្សេងទៀត?

Son: ទេម៉ាក់ លេង *ហ្វ៊ុតប៊ល* សប្បាយ ហើយពួកម៉ាកខ្ញុំទាំងអស់លេង *ហ្វ៊ុតប៊ល*។ លេង *ហ្វ៊ុតប៊ល* ទាស់អីម៉ាក់?

Mum: មើលមាឌឯងមើល៍ មាឌឯងមិនធំនិងរឹងមាំសមជាអ្នកលេង *ហ្វ៊ុតប៊ល* ទេ។
ម៉្យាងទៀតឯងនឹងអស់កំឡាំងខ្លាំងពេលត្រឡប់មកផ្ទះវិញ
រួចឯងនឹងថូរថាមិនអាចផ្ចង់គំនិតរៀនសូត្រ
បាន។

Son: ម៉ាក់ វាជាយប់ថ្ងៃសុក្រណា! ខ្ញុំមិនបាច់រៀនទេ។ ខ្ញុំគួរលំហែកាយយ៉ាងហោចណាស់ក៏ម្តងក្នុងមួយអាទិត្យដែរ។

Mum: ឆ្នាំនេះឯងត្រូវប្រឡងផង។ ឯងគួរតែខិតខំរៀនសូត្រអោយបានខ្លាំងបំផុតដែលអាចធ្វើទៅបាន ជាជាងដើរលេងសប្បាយច្រើនពេក។ ធ្វើម៉េចទៅ បើឯងមានគ្រោះថ្នាក់។ វានឹងអាចធ្វើអោយខូចអនាគតរបស់ឯងរហូត។ *ហ្វ៊ុតប៊ល* ជាកីឡាដែលត្រូវប្រើកំឡាំងខ្លាំង។ ឯងគួរសាកល្បងលេងកីឡាអ្វីផ្សេងវិញ។ បាល់បោះយ៉ាងម៉េចដែរ?

Son: ម៉ាក់ប្រហែលជានិយាយត្រូវ។ ខ្ញុំប្រហែលជានឹងគិតសាជាថ្មីក្រោយពីយប់ថ្ងៃសុក្រនេះ អូខេម៉ាក់? ចាំយើងនឹងពិភាក្សាគ្នានៅថ្ងៃស្អែក។

Mum: អញ្ចឹងក៏បានដែរ សំណាងល្អណា ហើយប្រយ័ត្នផងណាកូន!

***Text 6***

(Sinoun: female; Terry: male)

*(Ring, ring, ring)*

Terry: សួស្តីស៊ីនួន សុខសប្បាយទេ?

Sinoun: អ៊ំហា ធារី មិនអីទេអរគុណ។ ខ្ញុំគ្រាន់តែមិនសូវបានគេងលក់ច្រើនប៉ុណ្ណោះ។

Terry: ចុះកូនង៉ាដ៏ស្អាតរបស់ឯងយ៉ាងម៉េចហើយ? ឪពុកម្តាយឯងច្បាស់ជាស្រឡាញ់វាខ្លាំងណាស់មើលទៅ?

Sinoun: ឯងនិយាយត្រូវហើយ។ គាត់ទាំងពីរនាក់ស្រឡាញ់វាខ្លាំងណាស់។ រាល់ពេលដែលគាត់មកលេងម្តងៗ ខ្ញុំមិនចាំបាច់ធ្វើអ្វីទាំងអស់ដូចជា ដូរកន្ទប អោយទឹកដោះគោវា គាត់ថែមទាំងធ្វើម្ហូបអោយខ្ញុំទៀតផង។ ខ្ញុំមានសំណាងណាស់។

Terry: ម៉េចអញ្ចឹង? ខ្ញុំស្មានថាឯងជាអ្នកពូកែធ្វើម្ហូបម្នាក់?

Sinoun: ឯងដឹងហើយថាតាមទំនៀមទំលាប់ខ្មែរ គេជឿថា ស្ត្រីដែលទើបឆ្លងទន្លេរួចត្រូវតែញ៉ាំតាមមុខម្ហូបពិសេសម្យ៉ាងដើម្បីអោយមានសុខភាពល្អ មិនមែនសម្រាប់តែថ្ងៃនេះទេ គឺសម្រាប់ទៅថ្ងៃមុខទៀត ហើយនឹងដើម្បីរក្សារាងកាយនិងសម្បុរស្បែកទៀតផង។ ខ្ញុំសង្ឃឹមថាវាអាចជួយមែន។

Terry: តើវាជាចំណីអាហារបែបណាទៅ?

Sinoun: ចំណីភាគច្រើនត្រូវតែមានដាក់ខ្ញីឬម្រេច ទោះបីជាទឹកតែក៏ដោយ។ គេចាត់ទុកចំណីទាំងនោះជាចំណីក្តៅ។ ខ្ញុំមិនចូលចិត្តទេ ខ្ញុំស្ទើរតែលេបមិនរួច។

Terry: តើឯងអាចញ៉ាំស្អីផ្សេងទៀតបានទេ?

Sinoun: មិនទាំងអស់ទេ។ ចំណីដែលគេចាត់ទុកថាជាចំណីត្រជាក់ដូចជាត្រសក់និងត្រពាំងជាដើមមិនត្រូវមាននៅក្នុងមុខម្ហូបនេះទេ។

Terry: តើឯងធ្វើតាមគាត់ទេ?

Sinoun: មុនដំបូងប្ដីខ្ញុំនិងខ្ញុំមិនសូវជឿទេ ប៉ុន្តែខ្ញុំសម្រេចធ្វើតាមគាត់ ព្រោះវាគ្រាន់តែមួយខែប៉ុណ្ណោះ ខ្ញុំគ្មានអ្វីខាតបង់ទេ មិនអញ្ចឹងអ្វី?

Terry: និយាយអញ្ចឹង ខ្ញុំមិនដែលឃើញឯងនៅផ្សារសោះតាំងពីឯងមានកូនមក ម៉េចអញ្ចឹង?

Sinoun: ឯងមិនដឹងទេអ្វី ខ្ញុំមិនត្រូវចេញទៅណាក្រៅផ្ទះក្នុងអំឡុងមួយខែរហូតទាល់តែដល់ថ្ងៃពិធីចេញខែឯណោះ។ ខ្ញុំរង់ចាំថ្ងៃនោះខ្លាំងមែនទែនព្រោះខ្ញុំអផ្សុកណាស់។

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

**2019** PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2019

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the question that follows.

អស់លោក លោកស្រីជាទីមេត្រី! សូមស្វាគមន៍មកដល់ប្រាសាទកោង កាង។ ប្រាសាទនេះត្រូវបានគេរកឃើញនៅចុងសតវត្សទី២០ដោយក្រុមបុរាណវត្ថុវិទូបារាំងនិងខ្មែរ។

អស់ជាច្រើនពាន់ឆ្នាំមកហើយ ប្រាសាទនេះបិតនៅក្រោមដំបូកយ៉ាងធំមួយដែលមានដុំថ្មនិងដើមឈើដុះពីលើ ហើយមានដីស្រែព័ទ្ធជុំវិញដំបូកនោះ។ កសិករនៅតំបន់នេះតែងយកចំណីអាហារភេសជ្ជៈទៀនធូបមកដាក់កៀនដុំថ្មរាងបួនជ្រុងពីរដុំដែលមានកំពស់ប្រហែល៣០សង្ទីម៉ែត្រផុតពីដីនៅលើកំពូលដំបូកនោះដើម្បីបន់ស្រន់អោយកូនចៅរបស់គេជាពីជំងឺ។ គេទាំងឡាយមានជំនឿថា កន្លែងនេះជាកន្លែងរបស់ម្ចាស់ទឹកម្ចាស់ដីដែលជាអ្នកថែរក្សាទីនេះ។ ដោយបានទទួលពត៌មានពីចៅអធិការមួយអង្គគង់នៅវត្តក្បែរនេះ និងដោយប្រើឧបករណ៍ទាន់សម័យផង ក្រុមបុរាណវត្ថុវិទូបារាំងនិងខ្មែរបានចាប់ផ្តើមជីកដីចេញ ដោយគេជឿថាតាមពិតថ្មបួនជ្រុងទាំងពីរដុំនោះជាផ្នែកមួយនៃសរសរក្លោងទ្វាររបស់ប្រាសាទដែលត្រូវបានគេកប់ក្នុងដី។

គេប្រើពេលអស់ជាច្រើនឆ្នាំដើម្បីជីកយកប្រាសាទនេះចេញ ហើយចាប់សាងសង់វាឡើងវិញបន្តពីអ្វីដែលបានទុកចោលពីមុន។ សិលាចារឹកជាច្រើនត្រូវបានខូចខាតបាក់បែករាយប៉ាយឬបាត់បង់ជាច្រើន ដែលជាហេតុនាំអោយបុរាណវត្ថុវិទូជឿថាប្រាសាទនេះត្រូវបានគេបានសាងសង់មិនទាន់រួចនៅឡើយ ហើយជីដូនជីតាខ្មែរក៏បានបោះបង់វាចោលទៅ។ ទោះជាយ៉ាងនេះក្តីមានប្រជាជនខ្មែរជាច្រើននាក់ជឿតាមពាក្យចចាមអារាមដែលបានរាលដាលពេញប្រទេសថាមានប្រាសាទមួយទើបតែផុសចេញពីដីយ៉ាងអស្ចារ្យក្រៃលែង។

ឥឡូវណោះលោក លោកស្រីអាចចាប់ផ្តើមដើរមើលជុំវិញប្រាសាទ ហើយសូមមកជួបខ្ញុំវិញនៅទីនេះក្នុងរយៈពេល៣០នាទីទៀត។

QUESTION

**Marks**

Describe the beliefs about Prasat Kaung Karng for the *three* different groups of people mentioned in the text. **6**



PLEASE TURN OVER

8. Read the text and then answer in ENGLISH the question that follows.

## រឿងរបស់អ្នកស្រី សុធា ឈិន

នៅក្របខាងក្រោយសៀវភៅរបស់អ្នកស្រី សុធា ឈិន បានរៀបរាប់ថា "ខ្ញុំចង់បង្ហាញពិភពលោកថា ខ្ញុំអាចស្រោចស្រង់របាំប្រពៃណីបុរាណរបស់យើងកុំអោយសាបសូន្យ"។ សេចក្តីស្រម័យរបស់គាត់ដែលថានឹងបានធ្វើជាគ្រូរបាំបានក្លាយជាការពិត ប៉ុន្តែវាមិនបានដូចសេចក្តីប្រាថ្នាដែលគាត់បានសង្ឃឹមទុកពីមុន ដោយសារតែការអាក់ខានអស់រយៈពេល ៣ឆ្នាំ៨ខែ២០ថ្ងៃក្រោមរបបកុម្មុយនិស្តនៅប្រទេសកម្ពុជា។

*របាំប្រពៃណីបុរាណខ្មែរតែងតែនៅក្នុងបេះដូងរបស់ខ្ញុំជានិច្ច* គឺជាចំណងជើងនៃរឿងដ៏ស្រណោះមួយរបស់ស្ត្រីម្នាក់ដែលមានមហិច្ឆិតាចង់បញ្ជូនបន្តចំណេះដឹងដែលគាត់មានអំពីរបាំប្រពៃណីបុរាណខ្មែរដល់យុវជនជំនាន់ក្រោយ។ អ្នកស្រីជាអ្នករបាំមួយរូបក្នុងចំណោមអ្នករបាំល្បីឈ្មោះពីរបីនាក់ដែលបានរួចផុតពីរបបខ្មែរក្រហមនៅប្រទេសកម្ពុជា។ រឿងរបស់គាត់ចាប់ផ្តើមពីកុមារភាពរបស់គាត់ រួចបន្តទៅភាពជោគជ័យរបស់គាត់នៅសាលា សោកនាដកម្មរបស់គាត់ និងមធ្យោបាយដែលគាត់បានធ្វើដើម្បីអោយគាត់បានរស់រានមានជីវិតក្នុងរបបកម្មុយនិស្ត រួមជាមួយនឹងភាពប្តូរផ្តាច់របស់គាត់ក្នុងការបង្កើតសាលារបាំប្រពៃណីបុរាណខ្មែរនៅទីក្រុងភ្នំពេញពីបាទដៃទទេក្រោយពេលដែលរបបកម្មុយនិស្តត្រូវបានបញ្ចប់ភ្លាម។ ឥឡូវណោះគាត់សប្បាយរីករាយនឹងការបង្រៀនរបស់គាត់។

នេះជាសៀវភៅមួយដែលអ្នកត្រូវអាន។

QUESTION

**Marks**

How does the author try to persuade people to read Sothea Chhin's story? Support your answer with evidence from the text. **4**

**Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*

- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

> សួស្តីចំរើន!
>
> តើឯងសុខសប្បាយទេ? ខ្ញុំសង្ឃឹមថាឯងកំពុងខិតខំសិក្សាយ៉ាងខ្លាំងសម្រាប់ការប្រឡង។
>
> ខ្ញុំចង់ប្រាប់ឯងថាបន្តិចទៀតគ្រួសារខ្ញុំនឹងរើទៅរស់នៅកន្លែងដាច់ស្រយាលមួយនៃប្រទេសកម្ពុជា ដែលមានឈ្មោះថា សំឡូតដោយហេតុថាប៉ាខ្ញុំបានទទួលមុខងារថ្មីជាភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ចំនួនពីរឆ្នាំ។ វាបិតនៅឆ្ងាយប្រហែល៥០០គ.មពីកន្លែងដែលខ្ញុំរស់នៅសព្វថ្ងៃ។
>
> ឯងដឹងទេ ទីនោះគ្មានភ្លើងអគ្គិសនី គ្មានអ៊ិនធឺណិត គ្មានភោជនីយដ្ឋាន និងគ្មានរង្គសាលទេណ៎ា ប៉ុន្តែប៉ាម៉ាក់ខ្ញុំបានប្រាប់ខ្ញុំថាម្ហូបចំណីទាំងអស់សុទ្ធតែស្រស់ៗ មានធាតុអាកាសបរិសុទ្ធ និងមានមនុស្សរាក់ទាក់ល្អច្រើន ដូច្នេះហើយបានជាវាមិនមានអំពើឧក្រឹត្តកម្មនៅទីនោះទេ។ នៅទីនោះខ្ញុំត្រូវតែជិះកង់ទៅសាលារៀនរាល់ថ្ងៃ។ តើឯងយល់ថាខ្ញុំអាចរស់នៅបានដោយមិនមានទូរស័ព្ទដៃទេ? ខ្ញុំប្រាកដជានឹងនឹកជីដូនជីតានិងមិត្តភក្តិខ្ញុំទាំងអស់ណាស់។ ខ្ញុំនឹងមិនអាចទទួលអ៊ីមែលក្រោយថ្ងៃអាទិត្យនេះបានទេ ដូច្នេះសូមឆ្លើយតបមកខ្ញុំវិញជាប្រញាប់។
>
> គង់ថ្ងៃណាមួយឯងប្រហែលជានឹងអាចមកលេងនឹងខ្ញុំនៅសំឡូត។
>
> ពីខ្ញុំអារុន

QUESTION

You have just received this email from your close friend, Arun. Write an email responding to his concerns, reassuring him that he will be fine in Samlot, and suggesting how he can make the most of his experience there.

អ្នកទើបតែបានទទួលអ៊ីមែលនេះពីមិត្តជិតដិតរបស់អ្នកម្នាក់ឈ្មោះអារុន។ ចូរអ្នកសរសេរអ៊ីមែលមួយឆ្លើយតបទៅនឹងកង្វល់របស់គាត់ ដោយរៀបរាប់ធានាថាវានឹងមិនអីទេនៅសំឡូត ហើយនិងធ្វើសំណូមពរថាតើគាត់ត្រូវធ្វើយ៉ាងណាដើម្បីដកស្រង់យកបទពិសោធន៍របស់គាត់នៅទីនោះអោយបានល្អបំផុត។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question 9



PLEASE TURN OVER

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

2019 Public Examination

# Khmer

## Continuers Level

## Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2019

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. Some older members of your community in Australia are concerned that a number of younger members show little respect for Khmer traditions. You are a youth worker who has been asked to give a talk to the parents' group to help them better understand the younger generation.

    Write the text of your talk, discussing at least two traditions from the point of view of young people.

    សមាជិកចាស់ៗខ្លះនៃសហគមន៍របស់អ្នកនៅប្រទេសអូស្ត្រាលី បារម្ភថាយុវជនជំនាន់ក្រោយមួយចំនួនមិនសូវយកចិត្តទុកដាក់ទៅនឹងទំនៀមទំលាប់របស់ខ្មែរទេ។ អ្នកជាភ្នាក់ងារបម្រើផ្នែកយុវជនម្នាក់ត្រូវបានគេអោយនិយាយទៅកាន់ក្រុមមាតាបិតាដើម្បីជួយគាត់អោយបានយល់ច្បាស់កាន់តែប្រសើរអំពីយុវជនជំនាន់ក្រោយ។

    ចូរអ្នកសរសេរអត្ថបទនិយាយរបស់អ្នក ដោយធ្វើការពិភាក្សា នូវទំនៀមទំលាប់យ៉ាងតិចពីរយ៉ាងតាមទស្សនៈរបស់យុវជន។

11. You have decided to write an email to your friend in Cambodia about an event that you attended in Australia.

    Describe the event and suggest how the event might be improved for next year.

    អ្នកបានសម្រេចចិត្តសរសេរអ៊ីមែលមួយទៅកាន់មិត្តរបស់អ្នកនៅប្រទេសកម្ពុជាអំពីព្រឹត្តិការណ៍មួយដែលអ្នកបានចូលរួមនៅប្រទេសអូស្ត្រាលី។

    ចូរអ្នករៀបរាប់អំពីព្រឹត្តិការណ៍នោះ និងផ្តល់សំណូមពរដើម្បីធ្វើអោយព្រឹត្តិការណ៍នេះកាន់តែប្រសើរឡើងសម្រាប់ឆ្នាំក្រោយ។

12. You moved from Cambodia to Australia many years ago. You have decided to write an article for a Khmer community newspaper, evaluating the advantages and disadvantages of the multicultural society of Australia.

    Write your article.

    អ្នកបានផ្លាស់ពីប្រទេសកម្ពុជាមករស់នៅក្នុងប្រទេសអូស្ត្រាលីជាច្រើនឆ្នាំមកហើយ។ អ្នកបានសម្រេចចិត្តសរសេរអត្ថបទសម្រាប់ចុះផ្សាយក្នុងសារពត៌មានសហគមន៍ខ្មែរមួយ ដោយធ្វើការវាយតម្លៃអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់សង្គមពហុវប្បធម៌របស់ប្រទេសអូស្ត្រាលី។

    ចូរអ្នកសរសេរអត្ថបទរបស់អ្នក។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page. These notes will NOT be assessed.

This page is intentionally blank

Question Number:



PLEASE TURN OVER

**End of Section 3**